CAO COMPLIANCE ADVISOR OMBUDSMAN

*The Independent Accountability Mechanism for IFC & MIGA*

# របាយការណ៍ប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ

# អំពីបញ្ហាកង្វល់ទាក់ទងនឹង
# ការវិនិយោគរបស់ IFC ចំពោះធនាគារ ABBank (#29745, #40081)
# និង Vietinbank (#28509, #31300, #34124)
# និងបញ្ហាដែលបានលើកឡើងនៅកម្ពុជា

ខែមិថុនា ឆ្នាំ២០២២

ការិយាល័យតាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ

*សម្រាប់*

សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង

ទីភ្នាក់ងារធានាការវិនិយោគពហុតាគី

www.cao-ombudsman.org

## អំពីការិយាល័យ ស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យ សម្រាប់ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកនៃ ក្រុមធនាគារពិភពលោក។ ការិយាល័យ ស៊ីអេអូ រាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សានាយកប្រតិបត្តិ របស់ IFC និង MIGA។ ការិយាល័យ ស៊ីអេអូ មានអាណត្តិការងារសម្របសម្រួលដោះស្រាយ បណ្តឹងពីប្រជាពលរដ្ឋ ដែលអាចរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ក្នុងលក្ខណៈមួយដែលយុត្តិធម៌ ឥតលម្អៀង និង ប្រកបដោយភាពស្ថាបនា លើកកម្ពស់សមិទ្ធកម្មផ្នែកបរិស្ថាន និង សង្គមនៃគម្រោងទាំងនោះ ព្រមទាំងបង្កើន គណនេយ្យភាពសាធារណៈ និង ការរៀនសូត្រ សំដៅកែលម្អសមិទ្ធកម្មផ្នែកបរិស្ថាន និងសង្គម របស់ IFC/ MIGA និង កាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ចំពោះមនុស្ស និង បរិស្ថាន។

សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ www.cao-ombudsman.org

## តារាងមាតិកា

**១. សង្ខេប** ........ 1
**២. សាវតា** ........ 2
២.១ អំពីគម្រោង ........ 2
២.២ អំពីបណ្តឹង ........ 3
**៣. សង្ខេបអំពីការប៉ាន់ប្រមាណ** ........ 4
៣.១ វិធីសាស្ត្រ ........ 4
៣.២ សង្ខេបអំពីទស្សនៈ ........ 5
**៤. លទ្ធផលនៃការប៉ាន់ប្រមាណ និង ជំហានបន្ទាប់** ........ 8
**ឧបសម្ព័ន្ធ ក៖ ដំណើរការដោះស្រាយបណ្តឹងរបស់ការិយាល័យ ស៊ីអេអូ** ........ 9

# អក្សរកាត់

| | |
|---|---|
| ABBank | ធនាគារភាគហ៊ុនរួមទុនពាណិជ្ជ អាន ប៊ីញ (An Binh) |
| CAO | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ |
| EVN | ក្រុមហ៊ុនអគ្គិសនីវៀតណាម |
| EVNI | ក្រុមហ៊ុនភាគហ៊ុនរួមទុនអន្តរជាតិ EVN |
| FI | អន្តរការីហិរញ្ញវត្ថុ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| VietinBank | ធនាគារពាណិជ្ជភាគហ៊ុនរួមទុនវៀតណាមសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម |

## ១. សង្ខេប

នៅខែមិថុនា ឆ្នាំ២០១៨ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) បានទទួលពាក្យបណ្ដឹងដាច់ដោយឡែកពីគ្នា ចំនួនបី ដែលបណ្ដឹងទាំងនោះត្រូវបានធ្វើឡើងជំនួសឲ្យសហគមន៍ (“ដើមបណ្ដឹង”) ស្ថិតនៅខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ប្រទេសកម្ពុជា។ ដើមបណ្ដឹងមានទំនាក់ទំនងនឹងគម្រោងវារីអគ្គិសនីសេសានក្រោម ២ ដែលមានកម្លាំង ៤០០ មេហ្គាវ៉ាត់ (MW) ស្ថិតនៅក្នុងខ្សែទឹកនៃទន្លេសេសាន ក្នុងខេត្តស្ទឹងត្រែង។ ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការគម្រោងនេះ (“ប្រតិបត្តិករគម្រោង”) គឺជាអាជីវកម្មរួមទុនរវាងក្រុមហ៊ុនចិន គឺក្រុមហ៊ុន Hydrolancang International Energy Co. Ltd. ក្រុមហ៊ុនពហុផលិតផលនៃប្រទេសកម្ពុជា គឺ រ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុនភាគហ៊ុនរួមទុនអន្តរជាតិ EVN ដែលជាបុត្រសម្ព័ន្ធមួយរបស់ក្រុមហ៊ុនសេវាសាធារណៈនៃប្រទេសវៀតណាមគឺ ក្រុមហ៊ុនអគ្គិសនីវៀតណាម (EVN) ដែលកាន់កាប់ ១០ ភាគរយនៃក្រុមហ៊ុនដែលជាម្ចាស់គម្រោង។

ពាក្យបណ្ដឹងបានលើកឡើងអំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមមួយចំនួន ទាក់ទងនឹងគម្រោងវារីអគ្គិសនីសេសានក្រោម ២ រួមទាំងផលប៉ះពាល់ទាក់ទងនឹងការតាំងទីលំនៅថ្មីរបស់សហគមន៍ ផលប៉ះពាល់ទៅលើជីវភាពរស់នៅ ការគំរាមកំហែងចំពោះសមាជិកសហគមន៍ដែលមិនឯកភាពទៅនឹងគម្រោង ការខូចខាតចំពោះទីតាំងដែលមានសារសំខាន់ផ្នែកសង្គមវប្បធម៌ ដូចជាផ្នូរដូនតា និងព្រៃអារក្ស ព្រមទាំងផលប៉ះពាល់ទៅលើធនធានជលផលនៅក្នុងអាងទន្លេមេគង្គ អាងទន្លេសេសាន និងអាងទន្លេស្រែពក។ ដើមបណ្ដឹងនេះបានអះអាងថា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) មានភាពពាក់ព័ន្ធទៅនឹងគម្រោងនេះ តាមរយៈការវិនិយោគទៅលើអន្តរការីហិរញ្ញវត្ថុ (FI) នៅឯធនាគារ ABBank និង Vietinbank។ នៅខែកក្កដា ឆ្នាំ២០១៨ ការិយាល័យ ស៊ីអេអូ បានរកឃើញថា ពាក្យបណ្ដឹងមានលក្ខខណ្ឌសមស្រប ពាក់ព័ន្ធនឹងការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ លើអតិថិជនអន្តរការីហិរញ្ញវត្ថុទាំងពីរនេះ និង ការជាប់ពាក់ព័ន្ធទៅនឹងទំនប់វារីអគ្គិសនីដោយប្រយោល តាមរយៈការវិនិយោគក្នុងទំហំតិចតួចរបស់ធនាគារ ABBank នៅក្នុង EVNI និងការផ្ដល់ហិរញ្ញប្បទានរបស់ធនាគារ VietinBank ជូនដល់ EVN ។ ABBank និង VietinBank មិនយល់ស្របជាមួយ ការិយាល័យ ស៊ីអេអូ ដែលសម្រេចថាបណ្ដឹងមានលក្ខខណ្ឌសមស្រប ដើម្បីទទួលយកបណ្ដឹងនេះមកធ្វើការប៉ាន់ប្រមាណនោះទេ និងអះអាងថា ពួកគេគ្មានទំនាក់ទំនងទៅនឹងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ ឡើយ។ ពាក្យបណ្ដឹងក៏បានចោទប្រកាន់ផងដែរថា សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិជាប់ពាក់ព័ន្ធនឹងគម្រោងនេះ តាមរយៈអតិថិជនជាធនាគារទីបីមួយទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ការិយាល័យ ស៊ីអេអូ បានកំណត់ថា ចរិកលក្ខណៈនៃការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិទៅលើអតិថិជននោះមិនអាចមានការពាក់ព័ន្ធទៅនឹងគម្រោងនេះទេ។

អាស្រ័យដោយបណ្ដឹងទាំងបី លើកឡើងអំពីបញ្ហាដូចគ្នា ដូច្នេះការិយាល័យ ស៊ីអេអូ បានធ្វើការប៉ាន់ប្រមាណតាមរយៈដំណើរការតែមួយ ដែលមានការយល់ព្រមពីដើមបណ្ដឹង។ ក្នុងពេលប៉ាន់ប្រមាណ ដើមបណ្ដឹងបានបញ្ជាក់ឱ្យដឹងថាពួកគេមានបំណងចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទ ដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក ចំពោះកង្វល់របស់ពួកគេ។ ប៉ុន្តែ ប្រតិបត្តិករគម្រោងទំនប់វារី

អគ្គិសនីសេសានក្រោម ២ បានប្រាប់ឱ្យដឹងថា បើតាមការយល់ឃើញរបស់ពួកគេ ទិដ្ឋភាពផ្នែកបរិស្ថាន និង សង្គម នៃគម្រោងនេះ គឺជាកង្វល់របស់រដ្ឋាភិបាល ដូច្នេះ គេបានបដិសេធចំពោះការចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទ។ ស្របតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ការិយាល័យ ស៊ីអេអូ និងការរៀបចំអន្តរកាលក្រោមគោលនយោបាយថ្មីរបស់ការិយាល័យ ស៊ីអេអូ ពេលនេះបណ្តឹងត្រូវបានបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ ដើម្បីធ្វើការវាយតម្លៃសមិទ្ធកម្មផ្នែកបរិស្ថាន និង សង្គមរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ[1]។

# ២. សាវតា

## ២.១ អំពីគម្រោង

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានធ្វើការវិនិយោគមូលធនយ៉ាងសកម្មនៅក្នុង ABBank ដែលជាធនាគារពាណិជ្ជមួយនៅក្នុងប្រទេសវៀតណាម ដែលមានមូលធនទ្រព្យម្ចាស់ (quasi-equity) ជារូបិយប័ណ្ណដុង (D) ស្មើនឹង ៤០,៦ លានដុល្លារអាមេរិក និង ឥណទានសម្បទាន ប្រភេទ A ចំនួន ២៨,៥លាន ដុល្លារ (គម្រោងលេខ 29745 និង 40081 ដោយឡែកពីគ្នា)។ ការវិនិយោគនេះ បានស្នើឱ្យបង្កើតនូវទំនាក់ទំនងរយៈពេលវែងរវាង IFC និងធនាគារនេះ តាមរយៈការផ្តល់ហិរញ្ញប្បទានរយៈពេលវែង ដើម្បីបង្កើនគម្រោងឥណទានសម្បទានរបស់ខ្លួន ដោយផ្តោតលើសហគ្រាសធុនតូច និងមធ្យម (SMEs) និង SMEs ដែលមានស្ត្រីជាម្ចាស់ ព្រមទាំងអនុញ្ញាតឱ្យធនាគាររក្សាបាននូវផលធៀបមួយដ៏ល្អចំពោះមូលធនដែលមានភាពគ្រប់គ្រាន់។

IFC រួមជាមួយនឹងមូលនិធិមូលធននីយកម្ម IFC (មូលធនទ្រព្យម្ចាស់) និង មូលនិធិមូលធននីយកម្ម IFC (បំណុលរង) (ជារួមហៅថា "មូលនិធិរួម") ("Cap Fund") ក៏មានការវិនិយោគទៅលើមូលធនទ្រព្យម្ចាស់នៅក្នុងធនាគារ VietinBank របស់រដ្ឋ រហូតដល់រូបិយប័ណ្ណដុង ដែលមានតម្លៃស្មើនឹង ១៦៩,៦ ដុល្លារ

[1] ការប៉ាន់ប្រមាណរបស់ ការិយាល័យ ស៊ីអេអូ នេះ ត្រូវបានធ្វើឡើងស្របតាមគោលការណ៍ណែនាំប្រតិបត្តិ ឆ្នាំ២០១៣ និងយោងតាមមាត្រា ២.៣ ដែលចែងថា "ក្រោយពេលអនុវត្តដំណើរការប៉ាន់ប្រមាណរបស់ ការិយាល័យ ស៊ីអេអូ រួចរាល់ហើយ ប្រសិនបើគ្មានការយល់ព្រមចំពោះការដោះស្រាយវិវាទក្រោមការជួយសម្រួលរបស់ ការិយាល័យ ស៊ីអេអូ ទេនោះ ពាក្យបណ្តឹងនឹងបន្តទៅតួនាទីត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ"។
កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ក្រុមប្រឹក្សាភិបាលរបស់ IFC និង MIGA នៃនាយកប្រតិបត្តិ បានអនុម័ត គោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យថ្មីមួយ (ស៊ីអេអូ) របស់ IFC/MIGA ("គោលនយោបាយរបស់ ស៊ីអេអូ") ដែលបានឆ្លើយតបទៅនឹងអនុសាសន៍របស់*ការត្រួតពិនិត្យខាងក្រៅ ឆ្នាំ ២០២០ ទៅលើគណនេយ្យភាពរបស់ IFC/MIGA រួមទាំងតួនាទី និងប្រសិទ្ធភាពរបស់ ស៊ីអេអូ ផងដែរ* (ការត្រួតពិនិត្យពីខាងក្រៅ)។ ការអនុវត្តគោលនយោបាយថ្មីរបស់ការិយាល័យ ស៊ីអេអូ ដែលមានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ រួមបញ្ចូលការរៀបចំអន្តរកាល សម្រាប់សំណុំរឿងរបស់ការិយាល័យ ស៊ីអេអូ ដែលកើតឡើងមុនកាលបរិច្ឆេទនៃគោលនយោបាយនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់៖ https://www.cao-ombudsman.org/sites/default/files/downloads/CAOPolicy-TransitionalArrangements.pdf។ កថាខណ្ឌទី ៥៩ នៃគោលនយោបាយថ្មីរបស់ការិយាល័យ ស៊ីអេអូ ចែងថា "ប្រសិនបើភាគីទាំងពីរយល់ព្រមជ្រើសរើសយកការដោះស្រាយវិវាទនោះ ការិយាល័យ ស៊ីអេអូ នឹងជួយសម្រួលដល់ដំណើរការនេះ។ ប្រសិនបើគ្មានការយល់ព្រមទេនោះ ពាក្យបណ្តឹងនឹងបន្តទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ"។

(គម្រោងលេខ 28509, 31300 និង 34124)[2] ដែលក្នុងនោះគណនីរបស់ IFC មានចំនួន ៥៥,៦លាន ដុល្លារ។ ស្របពេលជាមួយគ្នានេះ មូលនិធិរួមនេះបានផ្តល់បំណុលបន្តចំនួន ១២៥លាន ដុល្លារ ទៅឱ្យធនាគារនេះដែរ។ ការវិនិយោគនេះត្រូវបានរំពឹងថានឹងជួយបង្កលក្ខណៈឱ្យធនាគារនេះអាច ក្លាយជាធនាគារ SME និងធនាគារផ្តល់ឥណទានខ្នាតតូចមួយដែលឈានមុខគេនៅក្នុងប្រទេស ព្រមទាំងគាំទ្រដល់ផែនការឯកជននីយកម្មរបស់រដ្ឋាភិបាលវៀតណាម សម្រាប់គ្រឹះស្ថាននេះផងដែរ។ IFC និងមូលនិធិរួម បានដកថយទាំងស្រុងពីការវិនិយោគនេះ កាលពីខែឧសភា ឆ្នាំ២០២១ និងបច្ចុប្បន្នពុំមាន ភាគហ៊ុនរបស់ធនាគារ VietinBank ទេ។

យោងតាមព័ត៌មានដែលការិយាល័យ ស៊ីអេអូ មាន និង ការកំណត់ថាមានលក្ខខណ្ឌសមស្រប ចំពោះបណ្តឹងដែលពាក់ព័ន្ធនឹងការវិនិយោគ[3] ដោយអន្តរការីហិរញ្ញវត្ថុរបស់ IFC ការិយាល័យ ស៊ីអេអូ បានរកឃើញថា IFC មានទំនាក់ទំនងដោយប្រយោលទៅនឹងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ តាមរយៈការវិនិយោគរបស់ខ្លួន ទៅលើធនាគារចំនួនពីរ ជាពិសេសគឺតាមរយៈ ការវិនិយោគក្នុងទំហំតិចតួចរបស់ធនាគារ ABBank នៅក្នុង EVNI និង ហិរញ្ញប្បទានរបស់ធនាគារ VietinBank ជូនដល់ EVN។ យ៉ាងណាក្តី ធនាគារទាំងពីរ និង IFC បានអះអាងថា ពួកគេគ្មានទំនាក់ទំនងជាមួយគម្រោងនេះឡើយ និងមិនឯកភាពទៅនឹងសេចក្តីសម្រេចរបស់ការិយាល័យ ស៊ីអេអូ ថាបណ្តឹងមានលក្ខខណ្ឌសមស្រប។

## ២.២ អំពីបណ្តឹង

ពាក្យបណ្តឹងទាំងបីដែលការិយាល័យ ស៊ីអេអូ ទទួលបាន នៅខែមិថុនា ឆ្នាំ២០១៨ ត្រូវបានធ្វើឡើងដោយអ្នកភូមិចំនួនបីក្រុមដាច់ដោយឡែកពីគ្នា ដែលលើកឡើងអំពីកង្វល់ផ្នែកសង្គម និងបរិស្ថានជាច្រើន ពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២។ ពាក្យបណ្តឹងត្រូវបានដាក់ទៅការិយាល័យ ស៊ីអេអូ ដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចំនួនបី រួមមាន អង្គការទន្លេអន្តរជាតិ (International Rivers) គម្រោងគណនេយ្យភាពអន្តរជាតិ (International Accountability Project) និង អង្គការឃ្លាំមើលទន្លេមេគង្គ (Mekong Watch) ដោយមានការយល់ព្រមពីដើមបណ្តឹង។ ដើមបណ្តឹងបានស្នើសុំឲ្យ ការិយាល័យ ស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។

ពាក្យបណ្តឹងបានលើកឡើងអំពីកម្រងបញ្ហាកង្វល់ផ្សេងៗគ្នា ពាក់ព័ន្ធនឹងសហគមន៍នីមួយៗ ក្នុងចំណោមសហគមន៍ទាំងបី ដែលរងផលប៉ះពាល់ដោយគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២។ ដើម្បីបណ្តឹងដែលបានប្តូរទីលំនៅថ្មីដោយសារគម្រោងនេះ អះអាងថា ពួកគេបានជួបប្រទះផលប៉ះពាល់ផ្នែកសង្គមគួរឱ្យកត់សម្គាល់ រួមទាំងកង្វះការពិគ្រោះយោបល់ និងការផ្តល់សំណងឱ្យបានគ្រប់គ្រាន់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពអន់ និង កង្វះលទ្ធភាពទទួលបានមុខរបរសម្រាប់ទ្រទ្រង់ជីវភាព នៅឯកន្លែងតាំងទីលំនៅ

[2] គម្រោងរបស់ IFC លេខ 31300 និង 34124 គឺជាបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមូលធនទ្រព្យម្ចាស់។ ជាទូទៅ IFC មិនបង្ហាញអំពីការវិនិយោគបន្ត ដែលធ្វើឡើងក្នុងគោលបំណងដូចគ្នាបែបនេះទេ។

[3] សូមមើលគោលនយោបាយរបស់ការិយាល័យ ស៊ីអេអូ 41a, https://documents1.worldbank.org/curated/en/889191625065397617/pdf/IFC-MIGA-Independent-Accountability-Mechanism-CAO-Policy.pdf

ថ្មី។ ដោយសារតែការដែលត្រូវប្តូរទីលំនៅទៅឆ្ងាយពីកន្លែងរស់នៅរបស់ពួកគេពីមុន ពួកគេក៏អះអាងផងដែរថា ពួកគេបានបាត់បង់លទ្ធភាពក្នុងការប្រើប្រាស់កន្លែងអារក្ស និងកន្លែងស័ក្តិសិទ្ធិនានារបស់ពួកគេ ដែលកន្លែងទាំងនេះសុទ្ធសឹងតែជាចំណែកមួយដ៏សំខាន់នៃជីវិតរស់នៅតាមបែបប្រពៃណីរបស់ពួកគេ។ ដើមបណ្តឹងដែលមិនព្រមប្តូរទៅរស់នៅឯកន្លែងតាំងទីលំនៅថ្មី អះអាងថាសន្តិសុខដីធ្លី និងជីវភាពរស់នៅរបស់ពួកគេបានរងផលប៉ះពាល់អវិជ្ជមានដោយគម្រោង ដោយសារកង្វះការផ្តល់សំណងសម្រាប់ការបាត់បង់ដី និងផ្ទះ ដែលជន់លិចក្រោយពេលប្រតិបត្តិការទំនប់។ បន្ថែមពីនេះទៀត ពាក្យបណ្តឹងក៏បានរៀបរាប់ផងដែរអំពីផលប៉ះពាល់ចរន្តខ្សែទឹកខាងលើ ទៅលើចំនួនធនធានជលផលនៅក្នុងអាងទន្លេសេសាន ទន្លេស្រែពក និងទន្លេមេគង្គ ការបាត់បង់ជីវភាពរស់នៅ ការកើនឡើងនៃភាពងាយរងគ្រោះទៅនឹងទឹកជំនន់ និង ការគំរាមកំហែងសមាជិកសហគមន៍ដែលមិនឯកភាពទៅនឹងគម្រោង។

នៅខែកក្កដា ឆ្នាំ២០១៨ ការិយាល័យ ស៊ីអេអូ បានរកឃើញថា ពាក្យបណ្តឹងមានលក្ខខណ្ឌសមស្រប[4] និងបានចាប់ផ្តើមធ្វើការប៉ាន់ប្រមាណ។ ទោះបីជាពាក្យបណ្តឹងបានបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់ការិយាល័យ ស៊ីអេអូ ថាមានលក្ខខណ្ឌសមស្របក៏ដោយ ក៏ការិយាល័យ ស៊ីអេអូ មិនធ្វើការវិនិច្ឆ័យណាមួយលើអង្គសេចក្តីនៃបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ក្នុងដំណាក់កាលដែលកំណត់ថាមានលក្ខខណ្ឌសមស្រប ឬ ដំណាក់កាលប៉ាន់ប្រមាណឡើយ ហើយការប៉ាន់ប្រមាណទៅលើបណ្តឹងក៏មិនបង្កប់អត្ថន័យថា IFC និងអតិថិជនរបស់ IFC ឬ អតិថិជនបន្តរបស់ IFC បានបង្កើតឱ្យមាននូវកំហុសណាមួយដែរ។

បញ្ហាដែលដើម្បីបណ្តឹង និង អតិថិជន/អតិថិជនបន្តរបស់ IFC ("គូភាគី") បានលើកឡើង ក្នុងពេលប៉ាន់ប្រមាណ មានពណ៌នាកាន់តែលម្អិតនៅខាងក្រោម។

# ៣. សង្ខេបអំពីការប៉ាន់ប្រមាណ

## ៣.១ វិធីសាស្រ្ត

ការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ មានបំណងធ្វើការស្វែងយល់ឲ្យកាន់តែច្បាស់អំពីបញ្ហា និងកង្វល់ដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹង តាមរយៈការពិភាក្សាជាមួយដើមបណ្តឹង អតិថិជន និង/ឬ អតិថិជនបន្តរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងភាគីពាក់ព័ន្ធដទៃទៀត។ ការិយាល័យ ស៊ីអេអូ ពន្យល់អំពីជម្រើសដែល

---

[4] នៅក្នុងការកំណត់ថាពាក្យបណ្តឹងមានលក្ខខណ្ឌសមស្រប ការិយាល័យ ស៊ីអេអូ បានត្រួតពិនិត្យឡើងវិញលើ៖ ១) ភាពពាក់ព័ន្ធរបស់ IFC ជាមួយអន្តរការីហិរញ្ញវត្ថុនីមួយៗ និង ២) ភាពពាក់ព័ន្ធរវាងអន្តរការីហិរញ្ញវត្ថុ និងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២។ ផ្អែកតាមព័ត៌មានដែលការិយាល័យ ស៊ីអេអូ អាចស្វែងរកបាន ពាក់ព័ន្ធនឹងចំណុច ១) ការវិនិយោគលើមូលធនរបស់ IFC នៅក្នុងធនាគារ ABBank និង VietinBank ធ្វើឲ្យ IFC ជាប់ពាក់ព័ន្ធទូទៅ ទៅនឹងគម្រោងទាំងមូលរបស់អន្តរការីហិរញ្ញវត្ថុនីមួយៗ។ ពាក់ព័ន្ធនឹងចំណុច ២) ការវិនិយោគរបស់ ABBank នៅក្នុង EVNI បង្ហាញឱ្យឃើញអំពីការពាក់ព័ន្ធទៅនឹងគម្រោង ដែលបានចាប់ផ្តើមក្នុងខែកញ្ញា ឆ្នាំ២០០៧ នៅពេលដែលធនាគារ ABBank បានចូលរួមជាស្ថាបនិកម្ចាស់ហ៊ុនតូច របស់ EVNI។ គប្បីកត់សម្គាល់ថា ធនាគារ VietinBank បានប្រាប់ឱ្យការិយាល័យ ស៊ីអេអូ ដឹងថា ខ្លួនមិនបានផ្តល់ហិរញ្ញប្បទានណាមួយទៅឱ្យ EVNI ទេ និងរាល់ហិរញ្ញប្បទានទាំងអស់របស់ខ្លួនជូនដល់ EVN ត្រូវបានដាក់កម្រិតកំណត់ចំពោះតែគម្រោងនៅក្នុងប្រទេសវៀតណាមប៉ុណ្ណោះ។

មាន ដល់គូភាគី និងជួយពួកគេកំណត់ថាតើពួកគេមានបំណងចង់ចាប់ផ្តើមដំណើរការដោះស្រាយវិវាទ ឬ ដំណើរការត្រួតពិនិត្យភាពអនុលោម របស់ការិយាល័យ ស៊ីអេអូ ដើម្បីដោះស្រាយបណ្តឹងនេះ។

នៅក្នុងករណីនេះ ការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ ចំពោះពាក្យបណ្តឹង រួមមានៈ

- ការត្រួតពិនិត្យឯកសារគម្រោងឡើងវិញ
- កិច្ចសន្ទនាតាមទូរសព្ទ និងកិច្ចប្រជុំដោយផ្ទាល់ជាមួយដើមបណ្តឹង និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលគាំទ្រពួកគេ
- កិច្ចសន្ទនាតាមទូរសព្ទជាមួយអ្នកតំណាងធនាគារដែលជាអតិថិជនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
- ការឆ្លើយឆ្លងសារ និងកិច្ចប្រជុំដោយផ្ទាល់ជាមួយតំណាងរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា និង
- កិច្ចសន្ទនាតាមទូរសព្ទ និងកិច្ចប្រជុំដោយផ្ទាល់ជាមួយក្រុមការងារគម្រោងរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។

បន្ទាប់ពីបានចាប់ផ្តើមការប៉ាន់ប្រមាណនៅឆ្នាំ២០១៨ ការិយាល័យ ស៊ីអេអូ បានពន្យាររយៈពេលធ្វើការប៉ាន់ប្រមាណ ក្នុងខែមករា ឆ្នាំ២០១៩ អាស្រ័យដោយត្រូវការបង្កើតទំនាក់ទំនងជាមួយក្រុមហ៊ុនដែលជាប្រតិបត្តិគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ និង សមភាគីរដ្ឋាភិបាល ដែលទស្សនៈរបស់ពួកគេត្រូវបានចាត់ទុកថាមានភាពពាក់ព័ន្ធ។ ដោយសារជំងឺរាតត្បាតសកល កូវីដ-១៩ និងការរឹតត្បិតលើការធ្វើដំណើរនៅក្រោយខែមីនា ឆ្នាំ២០២០ ការិយាល័យ ស៊ីអេអូ បានពន្យារពេលប៉ាន់ប្រមាណម្តងទៀតរហូតដល់ខែមករា ឆ្នាំ២០២១។ តាមការស្នើសុំរបស់ដើមបណ្តឹង ការិយាល័យ ស៊ីអេអូ បានពន្យារពេលប៉ាន់ប្រមាណបន្ថែមទៀតរហូតដល់ខែមករា ឆ្នាំ២០២២ ដើម្បីធានាពិនិត្យលទ្ធភាពឱ្យបានពេញលេញ ទៅលើសក្តានុពលក្នុងការដោះស្រាយវិវាទជាមួយរាល់ភាគីពាក់ព័ន្ធ។

## ៣.២ សង្ខេបអំពីទស្សនៈ

ផ្នែកនេះបង្ហាញអំពីទិដ្ឋភាពទូទៅទូលំទូលាយនៃបញ្ហា និងទស្សន ដែលគូភាគីបានបង្ហាញ ក្នុងអំឡុងពេលនៃការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ។

### *ទស្សនៈរបស់ដើមបណ្តឹង*

ពាក្យបណ្តឹងបានគូសបញ្ជាក់អំពីផលប៉ះពាល់ជាច្រើនលើអ្នកភូមិចំនួនបីក្រុមដាច់ដោយឡែកពីគ្នា ដែលរស់នៅខ្សែទឹកខាងក្រោម និងខាងលើនៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២។ សមាជិកជាច្រើននៃក្រុមទាំងនេះត្រូវបានកំណត់អត្តសញ្ញាណកម្មថាជាជនជាតិដើមភាគតិច ឬ ជនជាតិភាគតិច។ ដោយសារមានការបារម្ភអំពីការសងសឹកចំពោះការនិយាយអំពីគម្រោងនេះ សហគមន៍ទាំងបីបានស្នើសុំឲ្យការិយាល័យ ស៊ីអេអូ

មិនបង្ហាញអំពីអត្តសញ្ញាណសមាជិកសហគមន៍របស់ពួកគេ។[5] យោងតាមសំណើរបស់ពួកគេ យើងនឹងហៅពួកគេនៅក្នុងរបាយការណ៍បច្ចុប្បន្នថា ៖

ក. អ្នកភូមិតាំងទីលំនៅថ្មី មកពីភូមិក្បាលរមាសចាស់

ខ. អ្នកភូមិមកពីភូមិក្បាលរមាសចាស់ និង ភូមិស្រែគរចាស់ និង

គ. អ្នកភូមិមកពីស្រុកតាវែង លំផាត់ កូនមុំ អណ្តូងមាស និងវើនសៃ នៃខេត្តរតនគិរី ស្ថិតនៅតាមបណ្តោយទន្លេសេសាន និងទន្លេស្រែពក ដែលជាចរន្តខ្សែទឹកខាងលើនៃទន្លេសេសានក្រោម២។

អ្នកភូមិតាំងទីលំនៅថ្មី មកពីភូមិក្បាលរមាសចាស់ បានតាំងទីលំនៅថ្មីជាអចិន្ត្រៃយ៍ ដោយសារគម្រោង និងបានពន្យល់ទៅការិយាល័យ ស៊ីអេអូ ថាពួកគេមានអារម្មណ៍ថា ហេដ្ឋារចនាសម្ព័ន្ធដែលបានផ្តល់ជូនប្រជាពលរដ្ឋនៅឯកន្លែងតាំងទីលំនៅថ្មី ពុំមានភាពគ្រប់គ្រាន់។ ពួកគេបាននិយាយថា លក្ខខណ្ឌរស់នៅឯកន្លែងតាំងទីលំនៅថ្មី មានការលំបាក និងមិនដូចទៅនឹងអ្វីដែលមន្ត្រីរដ្ឋាភិបាលមូលដ្ឋានបានសន្យាពីមុន។ កង្វល់ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធមិនល្អនៅឯកន្លែងតាំងទីលំនៅថ្មី រួមមាន ការលើកឡើងអំពីការប្រើប្រាស់សម្ភារដែលមានគុណភាពទាបសម្រាប់សាងសង់ផ្ទះ ដែលធ្វើឱ្យផ្ទះទាំងនោះបាត់បង់លំនឹងសំណង់ និងខូចខាត ព្រមទាំងខ្វះប្រព័ន្ធលូដែលមានដំណើរការត្រឹមត្រូវ។ បន្ថែមពីនេះទៀត ដើមបណ្តឹងបានលើកឡើងអំពីកង្វះទឹកស្អាតប្រើប្រាស់ នៅក្នុងអណ្តូងដែលបានផ្តល់ជូននៅឯកន្លែងតាំងទីលំនៅថ្មី ជាពិសេសនៅរដូវប្រាំង និង ទឹកមានគុណភាពមិនល្អ ដែលនាំឱ្យមិនអាចប្រើប្រាស់សម្រាប់ទទួលទាន និងចំអិនអាហារបាន។ ដើមបណ្តឹងក៏បានចោទប្រកាន់ផងដែរថា មណ្ឌលសុខភាពនៅឯកន្លែងតាំងទីលំនៅថ្មី ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់ការថែទាំប្រកបដោយគុណភាព ជូនដល់អ្នកជំងឺទេ ជាពិសេសគឺចំពោះករណីជំងឺធ្ងន់ធ្ងរ។ គេបានអះអាងបន្ថែមទៀតថា ពួកគេមិនត្រូវបានផ្តល់ជូននូវកម្មវិធីស្តារជីវភាពរស់នៅ និងកិច្ចគាំទ្រនានាឡើយ រួមទាំងកិច្ចគាំទ្រផ្នែកប្រព័ន្ធធារាសាស្ត្រ និងការភ្ជួររាស់ដីស្រែចំការ និង ដីដែលមានសម្រាប់ធ្វើស្រែចំការ ពុំមានដើមឈើ ឬ ទីធ្លាសម្រាប់ចិញ្ចឹមសត្វ។ ពួកគេបានបង្ហាញឱ្យដឹងផងដែរអំពីបញ្ហាកង្វល់បន្ថែមទៀតឱ្យការិយាល័យ ស៊ីអេអូ បានដឹងអំពីកង្វះតម្លាភាព និងការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការបែងចែកដីធ្លី។

អ្នកភូមិមកពីភូមិក្បាលរមាសចាស់ និង ភូមិស្រែគរចាស់ រួមមានក្រុមប្រជាពលរដ្ឋដែលមិនយល់ព្រមតាំងទីលំនៅថ្មី និង ចាកចេញពីផ្ទះ និង មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដោយសារគម្រោង។ អ្នកភូមិក្បាលរមាសចាស់ បានកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិដើមភាគតិច និងមានបំណងការពារអត្តសញ្ញាណវប្បធម៌ និងកន្លែងស័ក្តិសិទ្ធរបស់ខ្លួន។ អ្នកភូមិមកពីភូមិស្រែគរចាស់ បានប្តឹងថាពួកគេខ្វះហេដ្ឋារចនាសម្ព័ន្ធ មូលដ្ឋាន

---

[5] ឆ្លើយតបនឹងការចោទប្រកាន់អំពីការគំរាមកំហែង និងការសងសឹងដែលដើមបណ្តឹងបានលើកឡើង ការិយាល័យ ស៊ីអេអូ បានធ្វើការប៉ាន់ប្រមាណ ស្របតាមគោលការណ៍នៃ*អភិក្រមរបស់ ការិយាល័យ ស៊ីអេអូ ដើម្បីឆ្លើយតបនឹងកង្វល់នៃការគំរាមកំហែង និងហេតុការណ៍នៃការសងសឹងនៅក្នុងប្រតិបត្តិការរបស់ ការិយាល័យ ស៊ីអេអូ។* សូមមើល www.cao-ombudsman.org/about-us/approach-reprisals ។ ការិយាល័យ ស៊ីអេអូ បានសន្និដ្ឋានថាមានហានិភ័យនៃការគំរាមកំហែង និងការសងសឹក ព្រមទាំងបានពិគ្រោះជាមួយដើមបណ្តឹង ដើម្បីពិភាក្សាអំពីវិធានការសមស្រប ដើម្បីការពារអត្តសញ្ញាណរបស់ពួកគេ និង កាត់បន្ថយហានិភ័យនៅក្នុងបរិបទនៃការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ។

និងពុំមានដីគ្រប់គ្រាន់ដើម្បីធ្វើស្រែចម្ការ ដោយសារទឹកជំនន់បង្កឡើងដោយគម្រោង និងដោយហេតុនេះ ពួកគេសូមទាមទារសំណង។ សហគមន៍ទាំងនេះបានពន្យល់មកការិយាល័យ ស៊ីអេអូ ថាពួកគេបានសង្កេតឃើញមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ចំពោះចំនួនធនធានជលផលនៅក្នុងតំបន់ដែលពួកគេរស់នៅ ដែលធនធាន ជលផលទាំងនេះគឺជាធនធានធម្មជាតិចម្បង ដែលពួកគេពឹងផ្អែកសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ ពួកគេប្រើប្រាស់ធនធានជលផលសម្រាប់ទទួលទានផ្ទាល់ខ្លួនផង និង សម្រាប់បង្កើតប្រាក់ចំណូលផង ដោយការលក់នៅឯទីផ្សារក្នុងស្រុក ព្រមជាមួយនឹងកសិផល និង អនុផលព្រៃឈើដទៃទៀត។

អ្នកភូមិមកពីស្រុកតាវែង លំផាត់ កូនមុំ អណ្តូងមាស និងវើនសៃ នៃខេត្តរតនគិរី ស្ថិតនៅតាមបណ្តោយទន្លេសេសាន និង ទន្លេស្រែពក ដែលជាចរន្តខ្សែទឹកខាងលើនៃទន្លេសេសានក្រោម២ បានពន្យល់ប្រាប់ការិយាល័យ ស៊ីអេអូ ថាគម្រោងនេះបានបណ្តាលឲ្យមានការប្រែប្រួលកម្ពស់ទឹក ដែលជាហេតុនាំឱ្យថយចុះធនធានជលផលនៅក្នុងទន្លេសេសាន និងទន្លេស្រែពក ដែលជាប្រភពអាហារូបត្ថម្ភ និងមុខរបរចិញ្ចឹមជីវិតសម្រាប់សហគមន៍។ អ្នកភូមិទាំងនេះក៏បានរាយការណ៍ឱ្យដឹងផងដែរថា ផលិតកម្មកសិកម្មរបស់ពួកគេ ការធ្វើចម្ការតាមមាត់ទន្លេ ការចុះទូក និងការចិញ្ចឹមសត្វ បានរងផលប៉ះពាល់អវិជ្ជមានដោយសារការប្រែប្រួលកម្ពស់ទឹកនេះ។

អ្នកភូមិទាំងបីក្រុមបានខិតខំចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទមួយ ដែលសម្របសម្រួលដោយការិយាល័យ ស៊ីអេអូ ដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទាំងអស់គ្នា សំដៅដោះស្រាយកង្វល់របស់ពួកគេ។ សមាជិកភូមិក្បាលរមាសចាស់ ដែលបានតាំងទីលំនៅថ្មី សង្ឃឹមថានឹងអាចស្វែងរកដំណោះស្រាយចំពោះកង្វល់ដែលទាក់ទងនឹងស្ថានភាពរស់នៅ នៅកន្លែងតាំងទីលំនៅថ្មីរបស់ពួកគេ រួមមានជាអាទិ៍ ការទទួលបានទឹកស្អាត និងអគ្គិសនី និងកិច្ចគាំទ្រក្នុងការផ្លាស់ប្តូរមុខរបរចិញ្ចឹមជីវិតថ្មី។ សមាជិកភូមិក្បាលរមាសចាស់ និងភូមិស្រែគរចាស់ ដែលបានបដិសេធចំពោះការតាំងទីលំនៅថ្មី សង្ឃឹមថានឹងអាចចូលរួមធ្វើការងារជាមួយប្រតិបត្តិករគម្រោង និងទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ នៅក្នុងដំណើរការនៃកិច្ចសហការស្វែងរកដំណោះស្រាយ ពាក់ព័ន្ធនឹងជីវភាពរស់នៅតាមបែបប្រពៃណីរបស់ពួកគេ និងសុវត្ថិភាពរបស់ពួកគេទាំងការរស់នៅ និងការប្រើប្រាស់ដីធ្លីដែលនៅក្បែរភូមិរបស់ពួកគេ និងគម្រោងទំនប់វារីអគ្គិសនី។ អ្នកភូមិមកពីស្រុកតាវែង លំផាត់ កូនមុំ អណ្តូងមាស និងវើនសៃ នៃខេត្តរតនគិរី ស្ថិតនៅតាមបណ្តោយទន្លេសេសាន និង ទន្លេស្រែពក ដែលជាចរន្តខ្សែទឹកខាងលើនៃទន្លេសេសានក្រោម២ មានបំណងចង់ទទួលបានព័ត៌មានបន្ថែមអំពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ដែលអាចកើតឡើង ដោយសារគម្រោង និងផែនការឆ្លើយតបនឹងគ្រោះអាសន្ន ប្រសិនបើមានបញ្ហាអវិជ្ជមានណាមួយកើតឡើងនៅទីតាំងគម្រោង។ ពួកគេក៏សង្ឃឹមថានឹងទទួលបានសំណង សម្រាប់ការបាត់បង់ជីវភាពរស់នៅរបស់ពួកគេ ដោយសារការធ្លាក់ចុះនៃធនធានជលផលផងដែរ។

ទោះបីជាមានសំណើសុំរក្សាការសម្ងាត់ក៏ដោយ ក៏ដើមបណ្តឹងបានបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំងលើការបង្កលក្ខណៈឱ្យមានការចូលរួមពីប្រតិបត្តិករគម្រោង នៅក្នុងដំណើរការដោះស្រាយវិវាទមួយ ដែលសម្របសម្រួលដោយការិយាល័យ ស៊ីអេអូ ដើម្បីព្យាយាម និងដោះស្រាយបញ្ហារបស់ពួកគេ។

*ទស្សនៈរបស់អតិថិជន/អតិថិជនបន្ត*

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងអតិថិជនអន្តរការីហិរញ្ញវត្ថុរបស់ IFC បានប្រកែកថាពួកគេគ្មានជាប់ពាក់ព័ន្ធទៅនឹងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ ឡើយ។ ABBank បានអះអាងថា ការជាប់ពាក់ព័ន្ធបន្តិចបន្តួចនៃមូលធនទ្រព្យម្ចាស់របស់ខ្លួន ទៅនឹង EVNI បានកើតឡើងមុនពេលសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិធ្វើការវិនិយោគនៅក្នុងធនាគារនេះ។ VietinBank បានជំទាស់ទៅនឹងការកំណត់របស់ការិយាល័យ ស៊ីអេអូ ថាខ្លួនជាប់ពាក់ព័ន្ធនឹងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ នៅពេលទទួលបានពាក្យបណ្តឹងនេះ ដោយបញ្ជាក់ថា ខ្លួនមិនបានផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុន EVN នៅក្រៅទឹកដីនៃប្រទេសវៀតណាមនោះទេ។

ក្នុងអំឡុងពេលប៉ាន់ប្រមាណ ការិយាល័យ ស៊ីអេអូ បានសន្ទនាជាមួយទាំងអតិថិជនអន្តរការីហិរញ្ញវត្ថុរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងអតិថិជនបន្តរបស់ពួកគេ ពោលគឺក្រុមហ៊ុន EVN។ ដោយមានការសម្របសម្រួលពីក្រុមហ៊ុន EVN អន្តរជាតិ ការិយាល័យ ស៊ីអេអូ ត្រូវបានប្រាប់ឱ្យដឹងថា ប្រតិបត្តិករគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ យល់ឃើញថា នៅក្នុងបរិបទនៃដំណើរការដោះស្រាយវិវាទរបស់ ការិយាល័យ ស៊ីអេអូនេះ រាជរដ្ឋាភិបាលកម្ពុជា គឺជាអ្នកដែលសមស្របជាងក្នុងការដោះស្រាយផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានរបស់គម្រោង។ បើទោះបីមានការព្យាយាមទាក់ទងទៅប្រតិបត្តិករគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ ជាច្រើនលើកច្រើនសារយ៉ាងណាក្តី ការិយាល័យ ស៊ីអេអូ មិនអាចទទួលបានកិច្ចសន្ទនាណាមួយជាមួយពួកគេ អំពីបណ្តឹងនេះបានឡើយ។ ដោយសារតែការិយាល័យ ស៊ីអេអូ មិនបានទទួលសញ្ញាណាមួយពីអតិថិជនអន្តរការីហិរញ្ញវត្ថុរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឬរាជរដ្ឋាភិបាលកម្ពុជា អំពីចំណាប់អារម្មណ៍ពួកគេក្នុងការចូលរួមក្នុងកិច្ចសន្ទនាជាមួយដើមបណ្តឹង ដូច្នេះ ការិយាល័យ ស៊ីអេអូ បានកំណត់ថា នៅក្នុងករណីនេះ ពុំមានការយល់ព្រមជាឯកច្ឆ័ន្ទ ដើម្បីចាប់ផ្តើមដំណើរការដោះស្រាយវិវាទនោះទេ។

## ៤. លទ្ធផលនៃការប៉ាន់ប្រមាណ និង ជំហានបន្ទាប់

លទ្ធផលនៃការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ កំណត់ថាតើពាក្យបណ្តឹងត្រូវផ្ទេរទៅមុខងារដោះស្រាយវិវាទ ឬ មុខងារត្រួតពិនិត្យភាពអនុលោម របស់ការិយាល័យ ស៊ីអេអូ។ បើទោះបីជាដើមបណ្តឹងបានខិតខំចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទដែលរៀបចំឡើងដោយការិយាល័យ ស៊ីអេអូ ក៏ដោយ ប៉ុន្តែ ទាំងអតិថិជនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង ប្រតិបត្តិករគម្រោង ពុំមានបំណងចូលរួមនៅក្នុងដំណើរការនេះទេ។ ដោយសារគូភាគីពុំមានការយល់ព្រមជាឯកច្ឆ័ន្ទចំពោះការចូលរួមដោយស្ម័គ្រចិត្តនៅក្នុងដំណើរការដោះស្រាយវិវាទ ដូច្នេះ ករណីនេះកំពុងបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូស្របតាមគោលនយោបាយរបស់ការិយាល័យ ស៊ីអេអូ។ ការវាយតម្លៃទៅលើភាពអនុលោមនឹងកំណត់ថាតើនឹងត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៅលើសមិទ្ធិកម្មរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែរឬទេ ឬ ការិយាល័យ ស៊ីអេអូ ត្រូវបិទករណីនេះ។ ឧបសម្ព័ន្ធផ្តល់នូវព័ត៌មានបន្ថែម ដែលបញ្ជាក់អំពីជំហានផ្សេងៗគ្នានៃដំណើរការត្រួតពិនិត្យភាពអនុលោម។

# ឧបសម្ព័ន្ធ ក៖ ដំណើរការដោះស្រាយបណ្តឹងរបស់ការិយាល័យ ស៊ីអេអូ

នៅពេលដែលការិយាល័យ ស៊ីអេអូ ប្រកាសថាពាក្យបណ្តឹងមួយមានលក្ខខណ្ឌសមស្របអាចទទួលយកបាន នៅពេលនោះមន្ត្រីឯកទេសផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ នឹងចុះធ្វើការប៉ាន់ប្រមាណបឋមមួយ។ ការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ មានគោលបំណង៖ (១) បញ្ជាក់អំពីបញ្ហា និងកង្វល់ដែល ដើមបណ្តឹងបានលើកឡើង (២) ប្រមូលព័ត៌មានអំពីការយល់ឃើញរបស់អ្នកពាក់ព័ន្ធដទៃទៀតចំពោះ ស្ថានភាព និង (៣) ជួយឱ្យអ្នកពាក់ព័ន្ធយល់អំពីជម្រើសឧបាស្រ័យ ឬ ដំណោះស្រាយ ដែលមានសម្រាប់ ពួកគេ និង សម្រេចថាតើពួកគេមានបំណងចង់ចូលរួមនៅក្នុងដំណោះស្រាយបែបសហការមួយ តាមរយៈ មុខងារដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ ឬ ថាតើករណីនោះគួរត្រូវបានត្រួតពិនិត្យដោយមុខងារ ផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ។

យោងតាមគោលនយោបាយនៃយន្តការគណនេយ្យភាពឯករាជ្យរបស់ IFC/MIGA (ការិយាល័យ ស៊ីអេអូ) [6] ជំហានខាងក្រោមត្រូវបានអនុវត្តតាមជាទូទៅ ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលទទួលបាន៖

ជំហានទី១៖ **ការបញ្ជាក់**ថាបានទទួលពាក្យបណ្តឹង។

ជំហានទី២៖ **លក្ខខណ្ឌសមស្របដែលអាចទទួលយកបាន។** ការកំណត់ថាតើពាក្យបណ្តឹងមានលក្ខខណ្ឌ សមស្របអាចទទួលយកបានដែរឬទេ ដើម្បីធ្វើការប៉ាន់ប្រមាណក្រោមអាណត្តិការងាររបស់ការិយាល័យ ស៊ីអេអូ (មិនឱ្យលើសពីរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ)។

ជំហានទី៣៖ **ការប៉ាន់ប្រមាណ**៖ ការប៉ាន់ប្រមាណទៅលើបញ្ហា និងការផ្តល់កិច្ច គាំទ្រជូនដល់អ្នកពាក់ព័ន្ធ ក្នុងការស្វែងយល់ និងការកំណត់ ថាតើពួកគេមានបំណងចង់ចូលរួមនៅក្នុងដំណោះស្រាយដែលមានការព្រមព្រៀងគ្នាតាមរយៈដំណើរការបែបសហការមួយ ដែលផ្តួចផ្តើមឡើងដោយមុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ ឬ ករណីនេះគប្បីត្រូវបានដោះស្រាយដោយមុខងារផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ ដើម្បីពិនិត្យឡើងវិញទៅលើការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ របស់ IFC/MIGA លើផ្នែកបរិស្ថាន និង សង្គម។ ការប៉ាន់ប្រមាណ អាចមានរយៈពេលអតិបរមា រហូតដល់ ៩០ថ្ងៃ នៃថ្ងៃធ្វើការ និងអាចពន្យារពេលបន្ថែមទៀត ច្រើនបំផុតត្រឹម ៣០ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើក្រោយរយៈពេល ៩០ថ្ងៃ នៃថ្ងៃធ្វើការ៖ (១) ភាគីបញ្ជាក់ថាទំនងអាចមានដំណោះស្រាយចំពោះបណ្តឹង ឬ (២) ភាគីណាមួយបង្ហាញអំពីចំណាប់អារម្មណ៍ចំពោះការដោះស្រាយវិវាទ និង មានសក្តានុពលដែលភាគីម្ខាងទៀតនឹងឯកភាព។

ជំហានទី៤៖ ការសម្របសម្រួលដោះស្រាយ៖ ប្រសិនបើគូភាគីជ្រើសរើសចូលរួមនៅក្នុងដំណើរការបែប សហការ ពេលនោះមុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ នឹងត្រូវផ្តួចផ្តើមឡើង។ ជាទូទៅ ដំណើរការដោះស្រាយវិវាទមានមូលដ្ឋានផ្អែកលើ ឬ ផ្តួចផ្តើមដោយអនុស្សរណៈនៃការយោគយល់គ្នាមួយ និង/ឬ វិធានមូលដ្ឋានដែលមានការឯកភាពព្រមព្រៀងគ្នា រវាងគូភាគី។ ដំណើរការនេះអាចពាក់ព័ន្ធការងារសម្របសម្រួល/សន្ទានកម្ម ការរួមគ្នាស្វែងរកការពិត ឬ អភិក្រម ដំណោះស្រាយដទៃទៀតដែលមានការឯកភាពព្រមព្រៀងគ្នា ដែលនាំឱ្យឈានទៅសម្រេចបាននូវ កិច្ចព្រមព្រៀងដោះស្រាយបញ្ហា ឬ គោលដៅដទៃទៀតដែលមាន

[6] សម្រាប់សេចក្តីលម្អិតបន្ថែមអំពីតួនាទី និងការងាររបស់ការិយាល័យ ស៊ីអេអូ សូមអានគោលនយោបាយទាំងស្រុងនៃយន្តការគណនេយ្យភាពឯករាជ្យរបស់ IFC/MIGA (CAO): https://documents.worldbank.org/en/publication/documents-reports/documentdetail/889191625065397617/ifc-miga-independent-accountability-mechanism-cao-policy

ការឯកភាពព្រមព្រៀងគ្នា និង គោលដៅដែលមានលក្ខណៈសមស្រប។ គោលបំណងចម្បងនៃប្រភេទអភិក្រមដោះស្រាយបញ្ហាទាំងនេះ គឺដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ព្រមទាំងបញ្ហាគួរឱ្យកត់សម្គាល់ដទៃទៀត ពាក់ព័ន្ធទៅនឹងពាក្យបណ្តឹង ដែលត្រូវបានកំណត់រកឃើញក្នុងអំឡុងពេលប៉ាន់ប្រមាណ ឬ ដំណើរការដោះស្រាយវិវាទ ក្នុងលក្ខណៈមួយដែលអាចទទួលយកបានចំពោះ ភាគីរងផលប៉ះពាល់។[7]

ឬ

**ការវាយតម្លៃ/ការស៊ើបអង្កេតទៅលើភាពអនុលោម៖** ប្រសិនបើគូភាគីជ្រើសរើសយកដំណើរការស៊ើបអង្កេត ពាក្យបណ្តឹងត្រូវបានបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ។ ពាក្យបណ្តឹងក៏ត្រូវបានបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមផងដែរ នៅពេលដែលដំណើរការដោះស្រាយវិវាទ នាំឱ្យទទួលបានការឯកភាពព្រមព្រៀងមួយផ្នែក ឬ គ្មានការឯកភាពព្រមព្រៀងទាល់តែសោះ។ យ៉ាងហោចណាស់ត្រូវមានដើមបណ្តឹងណាម្នាក់ ដែលត្រូវផ្តល់ការយល់ព្រមជាក់លាក់ សម្រាប់ការផ្ទេរនេះ លើកលែងតែការិយាល័យ ស៊ីអេអូ បានដឹងអំពីបញ្ហាកង្វល់ពាក់ព័ន្ធនឹងការគំរាមកំហែង និង ការសងសឹក។ មុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ ពិនិត្យទៅលើភាពអនុលោមរបស់ IFC/MIGA ទៅនឹងគោលនយោបាយបរិស្ថាន និងសង្គម ប៉ាន់ប្រមាណអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ និង ផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវ ក្នុងករណីសមស្រប ក្រោយពេលបញ្ចប់ដំណើរការមួយដែលមានបីជំហាន។ ទី១ ការវាយតម្លៃទៅលើភាពអនុលោម កំណត់ថាតើត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀត ដែរឬទេ។ ការវាយតម្លៃនេះអាចចំណាយពេលរហូតដល់ ៤៥ថ្ងៃ នៃថ្ងៃធ្វើការ និង អាចពន្យារពេលបន្ថែមទៀត ចំនួន ២០ថ្ងៃ នៃថ្ងៃធ្វើការក្នុងករណីពិសេស។ ទី២ ប្រសិនបើត្រូវធ្វើការស៊ើបអង្កេត គេត្រូវស៊ើបអង្កេតស៊ីជម្រៅទៅលើភាពអនុលោមនៃសមិទ្ធកម្មរបស់ IFC/MIGA បន្ទាប់ពីការវាយតម្លៃនេះ។ របាយការណ៍ស៊ើបអង្កេតមួយនឹងផ្សព្វផ្សាយជាសាធារណៈ ព្រមជាមួយនឹងការឆ្លើយតបរបស់ IFC/MIGA និង ផែនការសកម្មភាពមួយ ដើម្បីដោះស្រាយបញ្ហាគំហើញអំពីភាពមិនអនុលោម និង គ្រោះថ្នាក់ពាក់ព័ន្ធ។ ទី៣ ក្នុងករណីរកឃើញមានភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ ការិយាល័យ ស៊ីអេអូ នឹងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពឱ្យមានប្រសិទ្ធភាព។

ជំហានទី៥៖ **ការត្រួតពិនិត្យ និងតាមដាន។**

ជំហានទី៦៖ **សេចក្តីសន្និដ្ឋាន/ការបិទករណី។**

[7] ក្នុងករណីដែលអ្នកពាក់ព័ន្ធមិនអាចដោះស្រាយបញ្ហាបាន តាមរយៈដំណើរការបែបសហការ នៅក្នុងក្របខ័ណ្ឌពេលវេលាមួយដែលបានឯកភាពគ្នា ជាដំបូង ការដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ នឹងខិតខំជួយដល់អ្នកពាក់ព័ន្ធក្នុងការទម្លាយភាពជាប់គាំង នានា។ ប្រសិនបើសកម្មភាពនេះមិនអាចទៅរួច ក្រុមការងារដោះស្រាយវិវាទនឹងជូនដំណឹងដល់អ្នកពាក់ព័ន្ធ រួមទាំងបុគ្គលិករបស់ IFC/MIGA ប្រធាន និង ក្រុមប្រឹក្សាភិបាលនៃក្រុមធនាគារពិភពលោក និង សាធារណជនថា ផ្នែកដោះស្រាយវិវាទនៃការិយាល័យស៊ីអេអូ បានបិទពាក្យបណ្តឹងនេះ និង ផ្ទេរទៅឱ្យផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ ដើម្បីវាយតម្លៃ។

**ដំណើរការត្រួតពិនិត្យភាពអនុលោមត្រូវបានផ្តួចផ្តើម**

ដំណើរការត្រួតពិនិត្យភាពអនុលោមត្រូវ អាចត្រូវបានផ្តួចផ្តើមតាមវិធីចំនួន៣៖ គូភាគីជ្រើសរើសដំណើរការត្រួតពិនិត្យភាពអនុលោមក្រោយពេលប៉ាន់ប្រមាណរួចរាល់ ឬ ករណីត្រូវបានបញ្ជូនពីផ្នែកដោះស្រាយវិវាទ ឬ អគ្គនាយករបស់ការិយាល័យ ស៊ីអេអូ ផ្តួចផ្តើមធ្វើការត្រួតពិនិត្យភាពអនុលោម។

## 1 ការវាយតម្លៃ

ការិយាល័យ ស៊ីអេអូ ធ្វើការត្រួតពិនិត្យបឋមទៅលើសមិទ្ធិកម្មផ្នែកបរិស្ថាន និងសង្គមរបស់ IFC/MIGA និង គ្រោះថ្នាក់ពាក់ព័ន្ធ ដើម្បីកំណត់ថាតើបណ្តឹងត្រូវការឱ្យធ្វើការស៊ើបអង្កេតភាពទៅលើអនុលោម ដែរឬទេ។ ៤៥ថ្ងៃក្រោយមក ការិយាល័យ ស៊ីអេអូ បោះពុម្ពផ្សាយរបាយការណ៍មួយ ដែលបញ្ជាក់អំពីសេចក្តីសម្រេចចិត្តថានឹងធ្វើការស៊ើបអង្កេត ពន្យារ ឬ បិទករណី។

## 2 ការស៊ើបអង្កេត

ការិយាល័យ ស៊ីអេអូ ធ្វើការប្រមូល និងវាយតម្លៃភស្តុតាងអំពីសមិទ្ធិកម្មរបស់ IFC/MIGA ដោយយោងទៅតាមគោលនយោបាយផ្នែកបរិស្ថាន និងសង្គមរបស់ខ្លួន និង គ្រោះថ្នាក់នានាដែលពាក់ព័ន្ធទៅនឹងភាពមិនអនុលោម។ ដើមបណ្តឹង IFC/MIGA និង អតិថិជនរបស់ពួកគេអាចពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេត។ ប្រសិនបើរកឃើញថាមានភាពមិនអនុលោម ឬ គ្រោះថ្នាក់ ការិយាល័យ ស៊ីអេអូ នឹងផ្តល់អនុសាសន៍ដើម្បីដោះស្រាយបញ្ហាគ្រោះថ្នាក់នោះ និងបង្ការមិនឱ្យមានភាពមិនអនុលោមនៅពេលអនាគត។ IFC/MIGA រៀបចំផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង (MAP) ដោយពិគ្រោះយោបល់ជាមួយដើមបណ្តឹង និងអតិថិជនអំពីសកម្មភាពកែតម្រូវ ដើម្បីឆ្លើយតបទៅនឹងគំហើញពីការស៊ើបអង្កេតរបស់ការិយាល័យ ស៊ីអេអូ។

## 3 ការត្រួតពិនិត្យ

ការិយាល័យ ស៊ីអេអូ ត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង។ IFC/MIGA ផ្តល់របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការសកម្មភាព ទៅក្រុមប្រឹក្សាភិបាលរបស់ខ្លួន និង ការិយាល័យ ស៊ីអេអូ ធ្វើការបោះពុម្ពផ្សាយរបាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំរបស់ខ្លួន។

**បិទករណី**

នៅពេលដែលការិយាល័យ ស៊ីអេអូ កំណត់ថាសកម្មភាពនៅក្នុងផែនការត្រូវបានអនុវត្តរួចរាល់ ក្រោយពេលមានការចូលរួមជាមួយ IFC/MIGA ឬ ប្រសិនបើក្រុមប្រឹក្សាភិបាលរបស់ IFC/MIGA កំណត់ថាពុំមានការរំពឹងថានឹងមានសកម្មភាពបន្ថែមទៀតទេ ការិយាល័យ ស៊ីអេអូ នឹងបញ្ចេញរបាយការណ៍ត្រួតពិនិត្យចុងក្រោយ និងបិទករណី។